# ប្រភេទជំងឺដែលមានប្រភពមកពីសត្វព្រៃ

*ដោយៈ រដ្ឋបាលព្រៃឈើ*

## ១. ស្ថានភាពទូទៅ

បញ្ហាប្រឈមធំៗសម្រាប់សតវត្សទី ២១ ដែលពិភពលោកកំពុងជួបប្រទះគឺការប្រែប្រួលអាកាសធាតុ កំណើនប្រជាពលរដ្ឋ ភាពក្រីក្រ ការអត់ឃ្លាន សន្តិសុខស្បៀង ជំងឺឆ្លង និងការបំពុលបរិយាកាស។ នៅក្នុងដំណាក់កាលសាកលភាវូបនីយកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ចបានបង្កើនភាពទាក់ទង (contact) និងជម្លោះ (conflict) រវាងមនុស្ស–សត្វព្រៃកាន់តែច្រើន ជាហេតុធ្វើឲ្យមានការបាតបង់ចំនួន និងប្រភេទសត្វព្រៃកាន់តែកើនឡើង និងបង្កើនលទ្ធភាពឆ្លងជំងឺពីមនុស្ស–សត្វស្រុក–សត្វព្រៃ កាន់តែច្រើនឡើងដែលនាំឲ្យមានការយកចិត្តទុកដាក់កាន់តែច្រើនឡើងដល់ការការពារទប់ស្កាត់ និងបង្ការជំងឺដែលកើតមកពីសត្វព្រៃ។ មនុស្សគឺជាប្រភពផ្ទុកមេរោគនានានៅពេលដែលមនុស្សបង្កើនការតាំងទីលំនៅក្នុងតំបន់ថ្មីៗ ពួកគេបាននាំមកនូវប្រភេទសត្វចិញ្ចឹមរបស់ពួកគេដែលជាប្រភពបង្កមេរោគជំងឺថ្មីៗ ដល់ប្រព័ន្ធមជ្ឈដ្ឋាន ធម្មជាតិ (បរិស្ថាន) ហើយបន្តចម្លងទៅកន្លែងផ្សេងៗទៀតតាមរយៈចលនាចេញ–ចូលពីកន្លែងមួយទៅកន្លែងមួយទៀត។ ជាមួយគ្នានេះផងដែរ ជំងឺនានាដែលកើតមាននៅលើពិភពលោកយើងនេះ មាន៧៥ភាគរយ មានប្រភពមកពីសត្វ(សត្វស្រុក–សត្វព្រៃ)។



ជំងឺឆ្លងរបស់មនុស្ស និងសត្វស្រុក គេមានដំណោះស្រាយសម្រាប់ព្យាបាល ការពារទប់ស្កាត់ដោយឡែកៗ តាមប្រភេទជំងឺ ឆ្លងនីមួយៗ ផ្ទុយទៅវិញសម្រាប់ពពួកសត្វព្រៃគេមានដំណោះស្រាយបែបទូទៅ។ ដំណោះស្រាយជាប្រពៃណីរបៀបនេះសម្រាប់ ព្យាបាល ការពារទប់ស្កាត់ជំងឺឆ្លងដែលផ្តោតលើមនុស្ស និង សត្វស្រុក គឺមានលក្ខណៈចាស់គំរឹលហើយនាពេលបច្ចុប្បនេះ។ ជាការពិតណាស់ដែលគេត្រូវកែប្រែនូវរបៀប និងវិធីសាស្ត្រនៃការតាមដានលើជំងឺឆ្លង ដោយចាប់ផ្តើមធ្វើការអង្កេតលើប្រព័ន្ធមជ្ឈដ្ឋានបរិស្ថានជុំវិញ និងលក្ខណៈជីវសាស្ត្រនៃភ្នាក់ងារចម្លងជំងឺ។

កម្ពុជាជាប្រទេសកសិកម្ម និងជាគោលដៅទេសចរណ៍ អន្តរជាតិដ៏មានសក្តានុពល ហើយមានផែនការនាំចេញ–នាំចូល ច្រើនលើផលិតផលដែលមានដើមកំណើតពីសត្វស្រុក សត្វព្រៃ។ ដូច្នេះជាការសំខាន់ណាស់ដែលយើងត្រូវមានប្រព័ន្ធគ្រប់គ្រងការពារទប់ស្កាត់បង្ការជំងឺដែលកើត និងឆ្លងមកពីសត្វព្រៃ–សត្វ ស្រុក–មនុស្ស ការចូលរួមអនុវត្តនូវកាតព្វកិច្ចជាសមាជិកនៃ អង្គការសុខភាពសត្វពិភពលោក និងអង្គការពាណិជ្ជកម្មពិភពលោកដើម្បីកាត់បន្ថយនូវជម្លោះនានានៃការនាំចេញ–នាំចូលលើ ផលិតផល ដែលមានដើមកំណើតពីសត្វស្រុក–សត្វព្រៃ ដើម្បីយើងអាចចែករំលែក និងផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ វិធានការការពារទប់ស្កាត់បង្ការជំងឺដែលកើត និងឆ្លងមកពីសត្វព្រៃ–សត្វស្រុក–មនុស្ស ពីបណ្តាប្រទេសនានាក្នុងតំបន់ផងដែរ។

នាពេលកន្លងមក ពិភពលោកមានការយកចិត្តទុកដាក់ តិចតួចដល់ការសិក្សាស្រាវជ្រាវ ការពារទប់ស្កាត់ និងបង្ការជំងឺ ដែលកើតមកពីសត្វ ជាពិសេសនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍ និងប្រទេសក្រីក្រនានា។ តែបច្ចុប្បន្ននេះ គេបានចាប់ផ្តើមធ្វើការ តាមដានស្រាវជ្រាវដើម្បីរកឲ្យឃើញជាមុននូវជំងឺ ឬមេរោគនានា ដែលកើតពីសត្វស្រុក–សត្វព្រៃ ហើយឆ្លងទៅមនុស្ស–សត្វស្រុក ដើម្បីផ្តល់ឱកាសឲ្យមនុស្សជាតិមានវិធានការការពារការពាលដាល នៃជំងឺទាំងនោះ ហើយអាចការពារ និងទប់ស្កាត់នូវការបាត់បង់ សេដ្ឋកិច្ច សន្តិសុខស្បៀង អាយុជីវិតមនុស្ស–សត្វ និងប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិផងដែរ

ជំងឺមួយចំនួនដែលអាចកើតមកពីសត្វព្រៃនានាមានដូចជា High pathogenic Avian Influenza, Anthrax, SARS, Foot and mouth Disease, Rabies, Avian Cholera, Japanese Ensephalitis, Feral Swine Disease, Plague, West Nile Virus, Polio Small Pot, Ebola virus, Leishmaniasis, Yellow fever, Hanta viruses, AIDS, Leptospirosis, Brucellosis, Trichinellosis, Nipah virus, Tuberculosis។

ជំងឺដែលកើតពីសត្វ (ស្រុក ព្រៃ) ធ្វើឲ្យមានការប៉ះពាល់ ដល់ជីវិតមនុស្ស សត្វ និងសេដ្ឋកិច្ច ជាឧទាហរណ៍ ជំងឺអុតក្តាម Foot and mouth disease បានធ្វើឲ្យខាតថវិកា ១៤ ពាន់លានដុល្លារនៅសហរដ្ឋអាមេរិក ១១–១២ពាន់លានដុល្លារនៅចក្រភពអង់គ្លេស និង១៦០០ លានដុល្លារនៅតៃវ៉ាន់។ ជំងឺផ្តាសាយបក្សីបានធ្វើឲ្យពិភពលោកខាតបង់ថវិកាប្រមាណ ៣៥–៥០ ពាន់លានដុល្លារ។

## ២. ឧទាហរណ៍ខ្លះៗពីការបង្ការការចម្លង និងការបង្ការជំងឺដែលមានប្រភពមកពីសត្វជំងឺផ្តាសាយបក្សី

**Avian Influenza** ការបង្កជំងឺ ដោយសារមេរោគផ្តាសាយប្រភេទ A អនុប្រភេទ H5N1 ការចម្លងជំងឺ តាមការប៉ះពាល់ ឬបរិភោគសាច់បក្សីឈឺ ឬងាប់ដោយសារជំងឺផ្តាសាយបក្សីការបង្ការជំងឺ ទ្រុងសត្វត្រូវមានដំបូល និង





សំណាញ់ដើម្បីកាត់ផ្តាច់ទំនាក់ទំនងជាមួយសត្វស្លាបព្រៃ និងសត្វដទៃទៀត។ លាង សំអាតដៃបន្ទាប់ពីធ្វើការងារនៅក្នុងទ្រុង ឬប៉ះពាល់ជាមួយបក្សី ឈឺ ឬងាប់។ ត្រូវកប់ ឬដុតបក្សីដែលយើងសម្លាប់ចោល ឬងាប់។

**ជំងឺឆ្កួត (ឆ្កែឆ្កួត) Rabies**

ការបង្កជំងឺ ដោយវីរុសនៃជំងឺឆ្កួត ជាជំងឺដែលកើតនៅលើសត្វ ឆ្កែ ឆ្មា និងអាចលើពពួកសត្វមាំងសាសី និងពពួកជ្រើង ប្រជៀវ។





ការចម្លងជំងឺ ដោយសារសត្វដែលមានវីរុស (ឆ្កួត) ខាំ លិទ្ធ ឬក្រញៅ ។

ការបង្ការជំងឺ ឆ្កែ និងឆ្មា គួរចាក់វ៉ាក់សាំងនៅពេលដែលសត្វទាំងនោះមានអាយុ ២ខែ និងចាក់រំលឹកឡើងវិញតាមការណែនាំរបស់ បសុពេទ្យ។ បើសិនជាមានសត្វដែលសង្ស័យថាមានជំងឺឆ្កួត ខាំ លិទ្ធ ឬក្រញៅ លោកអ្នកត្រូវលាងសំអាតស្នាមរបួសជាមួយ សាប៊ូ និងទឹកហើយសូមប្រញាប់រួសរាន់ទៅជួបគ្រូពេទ្យជាបន្ទាន់។

**ជំងឺឈាមខ្មៅ (អង់ត្រាក់) Anthrax**

ការបង្កជំងឺ ដោយសារបាក់តេរី ស៊ីលូសអង់ត្រាក់ស៊ីស ដែលជា បាក់តេរីអាចបង្ករជាជំងឺលើពពួកថនិកសត្វទាំងអស់ជាពិសេស សត្វគោ ក្របី និងមនុស្ស។

ការចម្លងជំងឺ បាក់តេរី និង ស្ព័រ របស់មេរោគនេះ អាចចូលទៅក្នុងខ្លួនសត្វតាមរយៈការស៊ី ការដកដង្ហើម និងតាមស្នាមរបួស។

ការបង្ការជំងឺ កុំបរិភោគសាច់សត្វឈឺ ឬងាប់។ ត្រូវដុត ឬកប់សត្វងាប់យ៉ាងហោចណាស់ជម្រៅប្រហែល ១,៣ម៉ែត្រ។ ត្រូវបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែង និងជុំវិញកន្លែងដែលមានសត្វងាប់។





**ជំងឺប្រូសេឡូស Brucellosis**

ការបង្កជំងឺ ដោយសារបាក់តេរីឈ្មោះ ប្រូសេឡា។ មនុស្ស និងសត្វដែលបំបៅកូនដោយទឹកដោះ អាចឆ្លងនូវជំងឺនេះ។ ជំងឺនេះ អាចធ្វើឲ្យមេគោដើមពី៥ ដល់៨ ខែ រលូតកូនបាន ។

ការចម្លងជំងឺ ដោយសារការប៉ះពាល់ជាមួយទឹកដោះ ឬសាច់ដែលមានមេរោគនេះ ជាពិសេសជាមួយប្រដាប់បន្តពូជ ។

ការបង្ការជំងឺ ចាក់វ៉ាក់សាំងការពារគោ ក្របី នៅពេលដែលសត្វទាំងនោះមានអាយុចាប់ពី៣ ទៅ៦ខែ និងចាក់រំលឹកឡើងវិញ រៀងរាល់៦ខែម្តង ឬក៏មួយឆ្នាំម្តង។ក្នុងការបង្កាត់ពូជចូរប្រើប្រាស់គោ-ក្របីបា ឬទឹកស្ពែមពីគោ-ក្របីបា ដែលមានសុខភាពល្អ ដើម្បីជៀសវាងការឆ្លងជំងឺ ។





**ជំងឺលីបតូស្ពីរូស** **Leptospirosis**

ការបង្កជំងឺ ដោយសារបាក់តេរីឈ្មោះ លីបតូស្ពីរ៉ា។ មនុស្ស និងសត្វដែលបំបៅកូនដោយទឹកដោះជាញឹកញាប់ឆ្លងជំងឺនេះក្រោយពេលទឹកជំនន់ ។

ការចម្លងជំងឺ តាមរយៈស្បែក ។

ការបង្ការជំងឺ ជៀសវាងការឈរត្រាំក្នុងទឹកកខ្វក់ ឬទឹកភក់នៅតាមវាលស្រែ។ គួរពាក់ស្បែកជើងកៅស៊ូកវែង។ ចូរប្រុងប្រយ័ត្ន ចំពោះសត្វកណ្ដុរ ពីព្រោះសត្វនេះជាប្រភពនៃការចម្លងជំងឺ ។





**ជំងឺទ្រីជីណូស៊ីស ទ្រីជីណែលឡូស Trichinosis / Trichinellosis**

ការបង្កជំងឺ ដោយសារព្រូនមូលឈ្មោះទ្រីជីណែលឡា។ ព្រូនធំ រស់នៅតាមពោះវៀន ហើយពងព្រូននៅតាមសាច់ដុំជ្រូក ។

ការចម្លងជំងឺ តាមរយៈការបរិភោគសាច់ជ្រូកឆៅ។

ការបង្ការជំងឺ បរិភោគសាច់ជ្រូកដែលបានចំអិនឆ្អិនល្អ។ ទិញ ជ្រូក ឬផលិតផលពីសត្វជ្រូកពីកសិដ្ឋានដែលមានស្តង់ដារ។ ចូរបង្កើនវិធានជីវសុវត្ថិភាពនៅតាមកន្លែងចិញ្ចឹមសត្វជ្រូក ។





ករណីបាត់បង់សត្វគោព្រៃ ដែលជានិមិត្តរូបសត្វព្រៃកម្ពុជា ពីក្នុងធម្មជាតិក៏អាចបណ្ដាលមកពីបញ្ហាបាត់បង់ទីជម្រក ការបរបាញ់ហួសកម្រិត ឬអាចបណ្ដាលមកពីការឆ្លងជំងឺប្រភេទណាមួយ (អាចឆ្លងជំងឺក្នុងពូជ) ដែលធ្វើឲ្យប្រភេទសត្វគោព្រៃ នេះដាច់ពូជភ្លាមៗ (សត្វគោព្រៃរស់នៅរកស៊ីជាមួយហ្វូងសត្វ ទន្សោង និងខ្ទីង ហើយគេបានឃើញវត្តមានសត្វគោព្រៃចុងក្រោយ នៅឆ្នាំ ១៩៦៤ (Charles Warton, 1964) ប៉ុន្តែគេឃើញមាន

តែប៉ុណ្ណោះសត្វទន្សោង និងខ្ទីងនៅមានវត្តមាននៅឡើយនាពេលបច្ចុប្បន្ននេះ។

### ៣. សកម្មភាពការងារ

គួរកត់សម្គាល់ផងដែរថា នាពេលកន្លងមកនេះ នៅកម្ពុជា ពាក់ព័ន្ធនឹងការតាមដានជំងឺដែលមានប្រភពពីសត្វដូចជា ជំងឺផ្ដាសាយបក្សី ជំងឺផ្ដាសាយជ្រូកគឺមានតែផ្នែកសុខភាពសាធារណៈនិងផ្នែកបសុព្យាបាល (សុខភាពសត្វស្រុក) ដែលបានទទួលជំនួយធំៗពីប្រទេសផ្ដល់ជំនួយនានា និងតាមរយៈ ដៃគូអភិវឌ្ឍន៍នានាដូចជា FAO, WHO, OIE, USAID, JICA, EU, ADB & WB





Handling, Wild bird caught in mist net



Taking photo for bird identification

ប៉ុន្តែខាងផ្នែកសុខភាពសត្វព្រៃមិនបានទទួលការជួយលើកទឹកចិត្តឲ្យបានត្រឹមកម្រិតមូលដ្ឋានទេ។ នាពេលកន្លងមករដ្ឋបាលព្រៃឈើ បានទទួលតែគម្រោងសាកល្បងក្នុងការតាមដានជំងឺផ្ដាសាយបក្សីពីបក្សីព្រៃរួមទាំងការបណ្ដុះបណ្ដាល បឋមដែលឧបត្ថម្ភពីអង្គការ IDRC និង USDA ពីឆ្នាំ២០០៦-២០០៩ ក្នុងកម្រិតតិចតួចបំផុត។

ជាការឆ្លើយតបនឹងបញ្ហាជំងឺដែលអាចកើតមកពីសត្វព្រៃនាពេលបច្ចុប្បន្ននេះរដ្ឋបាលព្រៃឈើនិងដៃគូអភិវឌ្ឍន៍នានាបាននិងកំពុងបន្តធ្វើការសិក្សាស្រាវជ្រាវតាមដានពីជំងឺដែលអាចកើត មកពីសត្វព្រៃដូចជាជំងឺផ្ដាសាយបក្សី ផ្ដាសាយជ្រូក របេង ឆ្កួត សារ និងជំងឺនីប៉ាក្នុងកម្រិតជាគម្រោងសាកល្បង។ល។សកម្មភាពការងារនានា ដែលក្រុមការងារទទួលបន្ទុកសុខុមាលនិងសុខភាពសត្វព្រៃនៃរដ្ឋបាលព្រៃឈើកំពុងអនុវត្តនិងបន្តធ្វើពាក់ព័ន្ធនឹង ជំងឺដែលអាចកើតមកពីសត្វព្រៃរួមមាន:

ក. បង្កើនកិច្ចសហការ និងបណ្ដាញការងារ

ការតាមដានពីជំងឺឆ្លងនានាដែលមានប្រភពពីសត្វព្រៃនៅភូមិភាគអាស៊ីអាគ្នេយ៍ ជាពិសេសនៅប្រទេសកម្ពុជាគឺស្ទើរតែគ្មានសោះដោយសារការខ្វះខាតសមត្ថភាពនៃស្ថាប័នមានសមត្ថកិច្ច ទាំងផ្នែកធនធានមនុស្សថវិកា សម្ភារ ការសម្របសម្រួល រវាងស្ថាប័ន និងស្ថាប័ន ក៏ដូចជាមានលទ្ធភាពតិចតួចក្នុងការទាក់ចាប់សត្វព្រៃ ដើម្បីប្រមូលយកសំណាក (ឈាម ជាលិកា ទឹករងៃ និងលាមក។ល។) ដើម្បីយកទៅធ្វើការវិភាគពិសោធន៍។

– ជំរុញកិច្ចសហការរវាងបណ្ដាប្រទេស និងស្ថាប័ននានា ជាសមាជិកអង្គការសុខភាពសត្វពិភពលោក និងនៅក្នុងតំបន់ អាស៊ីប៉ាស៊ីហ្វិក លើការងាររាយការណ៍ពីស្ថានភាពសុខភាពសត្វព្រៃ និងការផ្ទុះជំងឺដែលកើតមកពីសត្វព្រៃ។ ធ្វើការសម្របសម្រួល និងទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងអ្នកឯកទេសនានាដូចជា អ្នកឯកទេសអភិរក្ស និងគ្រប់គ្រងសត្វព្រៃ ពេទ្យសត្វស្រុក ពេទ្យមនុស្សដើម្បីបង្កើនការយល់ដឹងបន្ថែមទៀតពីជំងឺដែលកើត ឬមានប្រភពមកពីសត្វព្រៃ ។

– ធ្វើការពិនិត្យតាមដានរួមគ្នាលើផលចំណេញដែលបានមកពីការការពារសុខភាពសត្វព្រៃដល់សង្គមសុខភាពសាធារណៈ និងបរិស្ថានវិធានការគ្រប់គ្រងសរុបចំពោះហានិភ័យនានានៃ សុខភាពមនុស្សជាតិ សត្វស្រុក សត្វព្រៃ ។

– រៀបចំបង្កើតបណ្ដាញអ្នកឯកទេសសត្វព្រៃនៅកម្ពុជា ដើម្បីធ្វើការប្រមូលផ្ដុំព័ត៌មាន ទិន្នន័យ ចែករំលែកបទពិសោធន៍ លើសកម្មភាពពិនិត្យតាមដាន និងការសិក្សាជំងឺដែលកើតមកពីសត្វព្រៃប្រមូលព័ត៌មាន

ទិន្នន័យ និងធ្វើរបាយការណ៍ស្ដីពីស្ថានភាពសុខភាពសត្វព្រៃ និងការផ្ទុះជំងឺដែលកើតមកពីសត្វព្រៃ ដើម្បីយើងមានវិធានការណ៍ទប់ស្កាត់ និងឆ្លើយតបទាន់ពេលវេលា ហើយអាចកាត់បន្ថយការបាត់បង់ផ្នែកសេដ្ឋកិច្ចធនធានសត្វ ស្រុក សត្វព្រៃ អាយុជីវិតមនុស្សជាតិ និងដើម្បីចូលរួមអនុវត្ត នូវកាតព្វកិច្ចជាសមាជិកនៃអង្គការសុខភាពសត្វពិភពលោក និង អង្គការពាណិជ្ជកម្មពិភពលោក ។

– ស្វែងរកការគាំទ្របច្ចេកទេស ថវិកាដល់ការតាមដាន និងការឆ្លើយតបក្នុងករណីផ្ទុះជំងឺ ជាពិសេសសម្រាប់ធ្វើការ សិក្សាស្រាវជ្រាវលើជំងឺជាអាទិភាពដែលមានលក្ខណៈស្រួចស្រាវ និងមានប្រភពមកពីសត្វដូចជា ជំងឺឈាមខ្មៅ (Anthrax) ជំងឺលីបតូស្ពីរ៉ូស (Leptospirosis) ជំងឺឆ្កែឆ្កួត (Rabies) CMgWnI)a: (Nipah) ។

ខ. ការរៀបចំលិខិតបទដ្ឋានបច្ចេកទេសផែនការ និងកម្មវិធីការងារ

– រៀបចំគោលការណ៍ណែនាំសម្រាប់ទប់ស្កាត់ និងបង្ការ ជំងឺជាអាទិភាពដែលមានប្រភពមកពីសត្វ

– ចាប់ផ្ដើមដំណើរការរៀបចំផែនការនៃកម្មវិធីសុខភាពសត្វព្រៃថ្នាក់ជាតិសម្រាប់តាមដានស្រាវជ្រាវជំងឺដែលកើត ឬមានប្រភពមកពីសត្វជាពិសេសពីសត្វព្រៃ ការអភិវឌ្ឍធនធានមនុស្ស វិធានការការពារទប់ស្កាត់ និងបង្ការជំងឺដែលកើតមកពីសត្វព្រៃនៅកម្ពុជា ។

–ការរៀបចំផែនការជាតិសម្រាប់តាមដានស្រាវជ្រាវជំងឺដែលកើតមកពីសត្វព្រៃ និងការអភិវឌ្ឍវិធានការការពារទប់ស្កាត់ និងបង្ការជំងឺដែលកើតមកពីសត្វព្រៃ។ ពាក់ព័ន្ធនឹងការ រៀបចំផែនការយុទ្ធសាស្ត្រជាតិស្ដីពី "ជំងឺមានប្រភពមកពីសត្វ "សម្រាប់ស្ថាប័នទាំងបី គឺក្រសួងសុខាភិបាលត្រូវរៀបចំជំពូក ពាក់ព័ន្ធនឹងសុខភាពសាធារណៈនាយកដ្ឋានផលិតកម្ម និង បសុព្យាបាលត្រូវរៀបចំជំពូកស្ដីពីសត្វស្រុក និងរដ្ឋបាលព្រៃឈើត្រូវរៀបចំជំពូកស្ដីពីសត្វព្រៃ។ បន្ទាប់ពីរៀបចំជំពូកនីមួយៗរួច ដៃគូអភិវឌ្ឍន៍ដូចជា អង្គការ WHO, FAO USAID និងជួយរៀបចំច្របាច់បញ្ចូលគ្នាជាឯកសារផែនការយុទ្ធសាស្ត្រជាតិដើម្បីធ្វើសុខដុមនីយកម្មនៃទំនាក់ទំនងរវាងមន្ត្រីសុខាភិបាល និងមន្ត្រីធ្វើការជាមួយសត្វ (សត្វស្រុក–សត្វព្រៃ) នៅគ្រប់លំដាប់ថ្នាក់ តាមស្ថានភាពជាក់ស្ដែង។

គ. ការបណ្ដុះបណ្ដាល និងពង្រឹងសមត្ថភាព

ជំនួយឧបត្ថម្ភទាំងផ្នែកបច្ចេកទេស ឧបករណ៍សម្ភារៈ ថវិកា និងការបណ្ដុះបណ្ដាលបច្ចេកទេសជំនាញសម្រាប់ការសិក្សាស្រាវជ្រាវពីជំងឺសត្វព្រៃដល់មន្ត្រីនាយកដ្ឋានសត្វព្រៃ និងជីវចម្រុះនិងមន្ត្រីរដ្ឋបាលព្រៃឈើនៅមូលដ្ឋាន គឺជាតម្រូវការចាំបាច់ និង ជាបន្ទាន់។

–រៀបចំការបណ្ដុះបណ្ដាលរួមគ្នាលើការតាមដាន និងឆ្លើយតបពាក់ព័ន្ធនឹងជំងឺដែលមានប្រភពពីសត្វ និងអំពីអន្តរទំនាក់ទំនងនៃសុខភាពមនុស្សជាតិ សត្វស្រុក សត្វព្រៃ និងបរិស្ថាន។

ឃ. ការអនុវត្តគម្រោងសាកល្បងក្នុងការស្រាវជ្រាវ និងតាមដានលើសុខភាពសត្វ

ដើម្បីមានលទ្ធភាពសម្រាប់ទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺឆ្លងនានាដែលមានប្រភពពីសត្វព្រៃ គឺពឹងផ្អែកជាសំខាន់ទៅលើសមត្ថភាពក្នុងការរកឃើញយ៉ាងរហ័សពីប្រភពនៃការចាប់ផ្ដើមឆ្លងនៃជំងឺនេះ ហើយក៏ជាផ្នែកមួយនៃការប្រឹងប្រែងសរុប របស់ស្ថាប័នពាក់ព័ន្ធនានាក្នុងការតាមដានលើពពួកសត្វព្រៃ។

–សិក្សាស្រាវជ្រាវទំនាក់ទំនងរវាងមនុស្សសត្វស្រុក សត្វព្រៃសុខភាពសាធារណៈ(ប្រភពប្រូតេអ៊ីនបានមកពីសត្វព្រៃ និង ចំណីអាហារមានប្រភពពីព្រៃធម្មជាតិ សន្តិសុខស្បៀង និងសង្គមមនុស្ស ទំនាក់ទំនងនៃសុខភាពមនុស្ស សុខភាពសត្វស្រុក–សត្វព្រៃ និងផលិតកម្មមានដើមកំណើតពីសត្វ(សត្វស្រុក និងសត្វព្រៃ)ការប្រឈមនឹងជំងឺឆ្លងនានាពីការធ្វើពាណិជ្ជកម្មអន្តរជាតិ

– ការសិក្សាពីវិភាគទាននៃការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងសត្វព្រៃដល់សុខភាពសាធារណៈ។

ង.ការត្រៀមសម្រាប់ឆ្លើយតបចំពោះការផ្ទុះជំងឺឆ្លងដែលមានប្រភពមកពីសត្វ

ការតាមដានការឆ្លងរាលដាលនៃជំងឺឆ្លងនានាដែលមានប្រភពពីសត្វព្រៃ តម្រូវឲ្យមានការចូលរួមក្នុងភាពជាដៃគូពីគ្រប់ស្ថាប័នពាក់ព័ន្ធនានា សង្គមស៊ីវិលមហាជនគ្រប់ជាន់ថ្នាក់ (ទាំងថ្នាក់កណ្ដាល ថ្នាក់ខេត្ត ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ) និងស្ថាប័នអ្នកផ្ដល់ជំនួយ

តាមលទ្ធភាព និងសមត្ថភាពជំនាញ។ល។

– រៀបចំបង្កើតយន្តការផ្លាស់ប្តូរព័ត៌មានលើការតាមដាន ជំងឺដែលមានប្រភពមកពីសត្វ (សត្វស្រុក សត្វព្រៃ)

– ការងារបង្ការជំងឺដែលកើតមកពីសត្វព្រៃនៅក្នុង និង ជុំវិញតំបន់ព្រៃឈើ

– រៀបចំបង្កើតប្រព័ន្ធរាយការណ៍ពីជំងឺដែលកើតមកពី សត្វព្រៃ។

## ៤. សន្និដ្ឋាន

បច្ចុប្បន្ននេះប្រទេសមួយចំនួនធំនៅក្នុងពិភពលោកយើងនេះបានចាប់ផ្តើមពិនិត្យ និងទទួលយកនូវទស្សនទាន និងគំនិតផ្តួចផ្តើម ពិភពលោកមួយ សុខភាពមួយ ថ្នាំព្យាបាលមួយ **"One World, One Health, One Medicine"** និងបន្ទាប់មក ហៅថាគំនិតផ្តួចផ្តើម ពិភពលោកមួយ សុខភាពមួយ **"One World, One Health Initiative"** ហើយចុងក្រោយ គេហៅបែបខ្លីថាគំនិតផ្តួចផ្តើម សុខភាពមួយ **"One Health Initiative"** ដែលមានការចូលរួមដោយអ្នកសត្វវិទ្យា អ្នកការពារ អភិរក្សព្រៃឈើ–សត្វព្រៃ ពេទ្យសត្វ ពេទ្យមនុស្ស សាស្ត្រាចារ្យ អ្នកស្រាវជ្រាវវិទ្យាសាស្ត្រ អ្នកធុរៈកិច្ច អ្នកឯកទេសការពារ និង គ្រប់គ្រងព្រៃឈើសត្វព្រៃ សុខភាពសាធារណៈ ហើយដែលមនុស្សជាតិ ត្រូវទទួលស្គាល់ថាជំងឺអាចឆ្លងពីសត្វព្រៃ–សត្វស្រុក– មនុស្ស និងការព្យាបាលក៏ត្រូវប្រើថ្នាំដូចគ្នា មិនថាមនុស្ស ឬ សត្វស្រុក សត្វព្រៃនោះទេ។

បើទោះបីជានាយកដ្ឋានសត្វព្រៃ និងជីវចម្រុះនៃរដ្ឋបាលព្រៃឈើមានផ្នែកមួយសម្រាប់សិក្សាពីជំងឺសត្វព្រៃហើយក៏ដោយ ក៏ប៉ុន្តែមកទល់បច្ចុប្បន្ននេះផ្នែកសិក្សាស្រាវជ្រាវតាមដានលើជំងឺសត្វព្រៃមិនទាន់សមត្ថភាពទាំងធនធានមនុស្ស ថវិកា និងឧបករណ៍សម្ភារសម្រាប់









អនុវត្តការងារឲ្យបានពេញលេញនៅឡើយទេ។

ការបារម្ភជាសកលគឺជំងឺឆ្លងនានាដែលមានប្រភពពីសត្វព្រៃអាចបង្កឲ្យមានការឆ្លងរាលដាលដល់មនុស្ស និងពីមនុស្ស ទៅមនុស្ស បន្ទាប់មកវាអាចបង្កឲ្យមានការស្លាប់រង្គាលដល់មនុស្ស (មហន្តរាយរបស់មនុស្សជាតិ)។ ការរៀបចំឲ្យមានប្រព័ន្ធ តាមដានជំងឺឆ្លងនានាដែលមានប្រភពពីសត្វព្រៃអាចជួយឲ្យយើងមានលទ្ធភាពទប់ស្កាត់ការឆ្លងជំងឺឆ្លងនានាដែលមានប្រភពពីសត្វព្រៃបានទាន់ពេលវេលា និងមានប្រសិទ្ធភាពដូចពាក្យចាស់លោកថា "ការពារប្រសើរជាងព្យាបាល " និងត្រូវមានវិធានការ បង្ការការពារទុកជាមុន មិនមែន "នៅពេលគោបាត់ទើបធ្វើរបង" នោះទេ។

## ឯកសារពិគ្រោះយោបល់ និងយោង


Forestry Administration (2011). Cambodia Wildlife-born Disease Surveillance, Monitoring, Research and Outbreak Rapid Response Plan. Phnom Penh, Cambodia.

World Organization for Animal Health-OIE (2009). Training Manual on Wildlife Diseases and Surveillance. Workshop for OIE National Focal Point for Wildlife. Paris, France.


ប្រភពរូបភាព ៖ នាយកដ្ឋានសត្វព្រៃនិងជីវចម្រុះ ការិយាល័យគ្រប់គ្រងទីជម្រក និងទេសចរណ៍ធម្មជាតិ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ភ្នំតាម៉ៅ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល អង្គការ **IDRC, OIE, USDA/APHIS, One Health Initiative.**